ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ព្រហស្បតិ៍ ៩ កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤*
*រាជធានីភ្នំពេញ, ថ្ងៃ ៣០ ខែ មេសា ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន
## កិច្ចប្រជុំពិសេសរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមួយវិស័យឯកជន ស្តីពី “ស្ថានភាពអាជីវកម្មនាពេលបច្ចុប្បន្ន និង វិធានការចាំបាច់នានា នៅក្នុងបរិបទជំងឺកូវីដ-១៩”

នាព្រឹកថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយវិស័យឯកជន ដើម្បីពិនិត្យ និងពិភាក្សាលើ “**ស្ថានភាពអាជីវកម្មនាពេលបច្ចុប្បន្ន និងវិធានការចាំបាច់នានា**” នៅក្នុងបរិបទដែលជំងឺកូវីដ-១៩ ដែលបាន និងកំពុងបន្តរីករាលដាលក្នុងតំបន់ និងសកល ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីធុរជនកម្ពុជា និងបរទេសសំខាន់ៗ មកពីវិស័យធនាគារ, ឧស្សាហកម្ម, ទេសចរណ៍, សំណង់, ឡូជីស្ទីក, សហគ្រាសធុនតូច និង មធ្យម, វិស័យស្រូវអង្ករ ។ល។

ការរីករាលដាលនៃជំងឺកូវីដ-១៩ បាន និងកំពុងគំរាមកំហែងកាន់តែខ្លាំងឡើងមកលើដំណើរការអាជីវកម្មក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា ដោយសារកំណើនសេដ្ឋកិច្ចតំបន់ និងសកល មានការថមថយជាពិសេស ការធ្លាក់ចុះនៃតម្រូវការក្នុងទីផ្សារខាងក្រៅ, ការបិទការធ្វើដំណើររបស់ប្រទេសក្នុងតំបន់ និងសាកលលោក និង ប្រសិទ្ធិភាពនៅមានកម្រិតនៃការអនុវត្តន៍វិធានការបង្ការ និងទប់ស្កាត់ការឆ្លងនៃជំងឺកូវីដ-១៩ ។ ទោះបីជាស្ថានភាពនៃជំងឺកូវីដនេះមានភាពប្រសើរឡើងវិញជាលំដាប់ រាជរដ្ឋាភិបាលកម្ពុជា បន្តយកចិត្តទុកដាក់ខ្ពស់ និងគិតគូរប្រកបដោយភាពបុរេសកម្មក្នុងការគ្រប់គ្រងជំងឺរាតត្បាតនេះ ព្រមទាំងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់សង្គម និងសេដ្ឋកិច្ច ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានសង្កត់ធ្ងន់ថា រាជរដ្ឋាភិបាលកម្ពុជាតែងតែចាត់ទុកវិស័យឯកជនជាចលករដ៏សំខាន់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងបង្កើតការងារជូនប្រជាពលរដ្ឋកម្ពុជា ។ ក្នុងបរិការណ៍ការរីករាលដាលនៃជំងឺកូវីដ-១៩ នេះ, រាជរដ្ឋាភិបាល និងវិស័យឯកជនកំពុងតែប្រឈមនឹងបញ្ហារួមក្នុងការបន្តលើកកម្ពស់កិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព ឬអាចនិយាយបានថា រាជរដ្ឋាភិបាល និងវិស័យឯកជនកំពុងធ្វើដំណើរក្នុង “**ទូកតែមួយ រួមសុខរួមទុក្ខជាមួយគ្នា**” ។ ក្នុងន័យនេះ, ការចូលរួមចំណែក

ក្នុងការរំលែកទុក្ខលំបាក និងដោះស្រាយបញ្ហាប្រឈមរួមចំពោះមុខ និងក្នុងការជួយស្តារការអភិវឌ្ឍប្រទេសកម្ពុជា ក្នុងអំឡុងពេលលំបាកនេះគឺជា "**កត្តាចាំ បាច់មិនអាចខ្វះបាន**" ។ ជាក់ស្តែង, រាជរដ្ឋាភិបាល បានដាក់ចេញនូវវិធានការអន្តរាគមន៍ចំនួន ០៣ ជុំ រួចមកហើយ ដើម្បីគ្រប់គ្រងផលប៉ះពាល់នៅក្នុងវិស័យសំខាន់ ៗ ដោយគិតគូរលើគ្រប់ទិដ្ឋភាពក្នុងការ÷

**ទី ១.** ជួយដល់ក្រុមហ៊ុន, រោងចក្រ, សហគ្រាស និងអាជីវកម្មដែលទទួលរងផលប៉ះពាល់ដើម្បី ឱ្យក្រុមហ៊ុនទាំងនោះអាចបន្តអាជីវកម្មបាន,

**ទី ២.** ជួយដល់កម្មករ-និយោជិតដែលបាត់បង់ ឬត្រូវព្យួរការងារឱ្យមានលំនឹងជីវភាព, និង

**ទី ៣.** ទ្រទ្រង់កំណើន ជាពិសេស ជួយដល់សហគ្រាសធុនតូចនិងមធ្យមដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ ។

ជារួម, វិស័យឯកជនបានវាយតម្លៃខ្ពស់ចំពោះវិធានការអន្តរាគមន៍ ដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញកន្លងមក ។ ទន្ទឹមនឹងនេះ, តំណាងពីធុរជនសំខាន់ៗ ក៏បានលើកឡើងអំពីការវាយតម្លៃស្ថានភាពធុរកិច្ចបច្ចុប្បន្ននៅកម្ពុជា និងលើកឡើងអំពីបញ្ហាប្រឈមដែលកំពុងបន្តជួបប្រទះក្នុងវិស័យនីមួយៗបន្ថែមទៀត និងបានស្នើជាវិធានការជូនរាជរដ្ឋាភិបាលពិចារណាផងដែរ សំដៅចូលរួមចំណែកស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ។ ជាមួយគ្នានេះ, វិស័យឯកជនក៏បានសម្តែងពីឆន្ទៈយ៉ាងមុះមុត និងការអត់ធ្មត់របស់ខ្លួន ក្នុងការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនានា ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំ បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលនឹងពិចារណាលើធាតុចូលទាំងនេះ ដើម្បីរៀបចំជាកញ្ចប់វិធានការអន្តរាគមន៍បន្តបន្ទាប់ទៀត ដើម្បីស្តារ និងជំរុញសេដ្ឋកិច្ចកម្ពុជា ។ វិស័យឯកជន និងរាជរដ្ឋាភិបាល ត្រូវបន្តសហការយ៉ាងជិតស្និតក្នុងការត្រៀមកំលាំងរួចជាស្រេច ក្នុងការចាប់យកកាលានុវត្តភាពថ្មីនានាដែលអាចកើតមានឡើងក្នុងអំឡុងពេល និងក្រោយវិបត្តិជំងឺកូវីដ-១៩ ។ ជាចុងក្រោយ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានថ្លែងអំណរគុណដល់វិស័យឯកជនដែលបានខិតខំប្រឹងប្រែងចូលរួម និងផ្តល់កិច្ចសហការយ៉ាងសកម្ម ជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។